MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


លេខ ៥៧៣៨ សហវ.ប្រក.២០២៤

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់សេវាសាធារណៈរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពនៃសេវា ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ ដែលភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

ឧបសម្ព័ន្ធ១ : ជាកម្រងសេវាសាធារណៈ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ឧបសម្ព័ន្ធ២ : ជាកម្រងសេវាសាធារណៈ ដែលក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត។

**ប្រការ២ .–**

ទម្រង់បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់សេវាសាធារណៈទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ត្រូវអនុវត្តតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៣ .–**

ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងលេខ៥៥៩ សហវ.ប្រក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យជាប្រាក់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ហែម វណ្ណឌី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## កម្រងសេវាសាធារណៈ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | I. | **អគ្គនាយកដ្ឋានឧស្សាហកម្ម** | | | |
| | ក. | **នាយកដ្ឋានកិច្ចការឧស្សាហកម្ម** | | | |
| ១ | ១- | ប្រកាសបង្កើតរោងចក្រ ឬសាខារោងចក្រ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ២ ០០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | ២- | ការផ្តល់វិញ្ញាបនបត្រថ្មី និងបន្ត (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ៨០០ ០០០ | ៧ថ្ងៃ | ៣ឆ្នាំ |
| ៣ | ៣- | លិខិតបញ្ជាក់លើ ការពង្រីកផលិតកម្ម ឬការប្តូរទីតាំងរោងចក្រ ឬការប្តូរម្ចាស់ភាគហ៊ុន ឬការប្តូរឈ្មោះរោងចក្រ ឬការបន្ថែមមុខផលិតផលថ្មី | ១ ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ៤ | ៤- | ចុះបញ្ជីរោងចក្រ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ១ ០០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ៥ | ៥- | លិខិតបញ្ជាក់ទុតិយតា | ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ៦ | ៦- | លិខិតបញ្ជាក់ផ្សេងទៀតចាំបាច់មានដូចជា ការវិនិយោគរោងចក្រ ភាពជាម្ចាស់គម្រោង ការបញ្ជាក់ទំនិញប្រភពដើម និងបរិមាណប្រើប្រាស់ និងការបញ្ជាក់ធាតុចូលផលិតកម្ម | ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| | ខ. | **នាយកដ្ឋានបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម** | | | |
| | ១- | លិខិតបញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មលើឡចំហាយ ម៉ាស៊ីនភ្លើង គ្រឿងចក្រ និងខ្សែសង្វាក់ផលិតកម្ម | | | |
| ៧ | - | រោងចក្រ | ១ ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៨ | - | សហគ្រាសធុនតូចនិងមធ្យម | ៤០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៩ | - | សិប្បកម្ម | ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១០ | ២- | លិខិតបញ្ជាក់លើបរិមាណប្រើប្រាស់វត្ថុធាតុដើម ឧបករណ៍បរិក្ខារ និងមុខសញ្ញាប្រើប្រាស់ -រោងចក្រ | ១ ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ១១ | ៣- | លិខិតបញ្ជាក់លើបរិមាណប្រើប្រាស់វត្ថុធាតុដើម ឧបករណ៍បរិក្ខារ និងមុខសញ្ញាប្រើប្រាស់ -សហគ្រាសធុនតូចនិងមធ្យម | ៤០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ១២ | ៤- | លិខិតបញ្ជាក់លើបរិមាណប្រើប្រាស់វត្ថុធាតុដើម ឧបករណ៍បរិក្ខារ និងមុខសញ្ញាប្រើប្រាស់-សិប្បកម្ម | ២០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ១៣ | ៥- | លិខិតបញ្ជាក់លើការរៀបចំប្រព័ន្ធប្រព្រឹត្តកម្ម ការទុកដាក់សំណល់រាវ សំណល់រឹង ឧស្ម័ន និងប្រព័ន្ធលំហូរខ្យល់ ដែលខុសពីលក្ខណៈបច្ចេកទេស ដែលកំណត់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១ ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | គ. | **នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម** | | | |
| | គ.១- | **ការផ្តល់ប្រកាសនីយបត្រតក្កកម្ម** | | | |
| ១៤ | ១- | ការស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម-សេចក្តីអះអាង ១០ដំបូង | ៣២០ ០០០ | ១០ថ្ងៃ | |
| ១៥ | ២- | ការស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម-សេចក្តីអះអាងលើសពី ១០ដំបូង | ២០ ០០០ | ១០ថ្ងៃ | |
| ១៦ | ៣- | ការផ្តល់ប្រកាសនីយបត្រតក្កកម្ម | ៦០០ ០០០ | ១០ថ្ងៃ | ២០ឆ្នាំ |
| ១៧ | ៤- | ការផ្តល់វិញ្ញាបនបត្រទុតិយតាប្រកាសនីយបត្រតក្កកម្ម និងម៉ូដែលមានអត្ថប្រយោជន៍ | ១០០ ០០០ | ១០ថ្ងៃ | ដូចវិញ្ញាបនបត្រចាស់ |
| ១៨ | ៥- | ការផ្តល់អាជ្ញាបណ្ណបញ្ចា | ១ ៥០០ ០០០ | ១០ថ្ងៃ | ២ឆ្នាំ |
| ១៩ | ៦- | ការបញ្ជាក់លើការកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណ ឬប្តូរម្ចាស់កម្មសិទ្ធិ | ២៨០ ០០០ | ១០ថ្ងៃ | |
| ២០ | ៧- | ការបញ្ជាក់លើឯកសារប្រកាសសិទ្ធិអាទិភាព | ៣០០ ០០០ | ១០ថ្ងៃ | |
| ២១ | ៨- | ការសុំកែប្រែឈ្មោះ អាសយដ្ឋាន និងការផ្លាស់ប្តូរផ្សេងៗ របស់ភ្នាក់ងារតំណាង ឬអ្នកដាក់ពាក្យសុំ | ៤០ ០០០ | ១០ថ្ងៃ | |
| ២២ | ៩- | ការស្តារឡើងវិញនូវសុពលភាពការពារប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | ១០០ ០០០ | ១០ថ្ងៃ | |

| លេខរៀងសេវា | បរិយាយ | | តម្លៃឯកតា នៃសេវា (រៀល) | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ១០- | ការបង់កម្រៃប្រចាំឆ្នាំ ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងប្រកាសនីយបត្រតក្កកម្ម (ចាប់ពីរយៈពេល១ឆ្នាំ ក្រោយកាលបរិច្ឆេទស្នើសុំ) | | | |
| ២៣ | - | ឆ្នាំទី២ | ៨០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២៤ | - | ឆ្នាំទី៣ | ១២០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២៥ | - | ឆ្នាំទី៤ | ១៦០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២៦ | - | ឆ្នាំទី៥ | ៤០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២៧ | - | ឆ្នាំទី៦ | ៥៦០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២៨ | - | ឆ្នាំទី៧ | ៧២០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ២៩ | - | ឆ្នាំទី៨ | ៨៨០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣០ | - | ឆ្នាំទី៩ | ១ ០៤០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣១ | - | ឆ្នាំទី១០ | ១ ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣២ | - | ឆ្នាំទី១១ | ១ ៤០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣៣ | - | ឆ្នាំទី១២ | ១ ៦០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣៤ | - | ឆ្នាំទី១៣ | ១ ៨០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣៥ | - | ឆ្នាំទី១៤ | ២ ០០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣៦ | - | ឆ្នាំទី១៥ | ២ ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣៧ | - | ឆ្នាំទី១៦ | ២ ៤៤០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣៨ | - | ឆ្នាំទី១៧ | ២ ៦៨០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៣៩ | - | ឆ្នាំទី១៨ | ២ ៩៦០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៤០ | - | ឆ្នាំទី១៩ | ៣ ២៤០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៤១ | - | ឆ្នាំទី២០ | ៣ ៥៦០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៤២ | ១១- | ត្រូវបង់កម្រៃបន្ថែម ចំពោះការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម ក្នុងដំណាក់កាលជាតិចន្លោះលើសពី ៣០ខែដល់៣២ខែ | ១២០ ០០០ | ១០ថ្ងៃ | |
| | គ.២- | **ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍** | | | |
| ៤៣ | ១- | ការស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ - សេចក្តីអះអាង ១០ដំបូង | ១៦០ ០០០ | ១០ថ្ងៃ | |
| ៤៤ | ២- | ការស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ - សេចក្តីអះអាងលើសពី ១០ដំបូង | ២០ ០០០ | ១០ថ្ងៃ | |
| ៤៥ | ៣- | ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | ២០០ ០០០ | ១០ថ្ងៃ | ៧ឆ្នាំ |
| ៤៦ | ៤- | ការបញ្ជាក់លើការកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណ ឬប្តូរម្ចាស់កម្មសិទ្ធិ | ២០០ ០០០ | ១០ថ្ងៃ | |
| ៤៧ | ៥- | ការបញ្ជាក់លើឯកសារថតចម្លង | ៤០ ០០០ | ៧ថ្ងៃ | |
| ៤៨ | ៦- | ការស្នើសុំអាជ្ញាបណ្ណបញ្ជា | ១ ០០០ ០០០ | ១០ថ្ងៃ | |
| | ៧- | ការបង់កម្រៃប្រចាំឆ្នាំ ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (ចាប់ពីរយៈពេល១ឆ្នាំក្រោយកាលបរិច្ឆេទស្នើសុំចុះបញ្ជី) | | | |
| ៤៩ | - | ឆ្នាំទី២ | ៨០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៥០ | - | ឆ្នាំទី៣ | ១០០ ០០០ | ៧ថ្ងៃ | |
| ៥១ | - | ឆ្នាំទី៤ | ១២០ ០០០ | ៧ថ្ងៃ | |
| ៥២ | - | ឆ្នាំទី៥ | ២០០ ០០០ | ៧ថ្ងៃ | |
| ៥៣ | - | ឆ្នាំទី៦ | ៣០០ ០០០ | ៧ថ្ងៃ | |
| ៥៤ | - | ឆ្នាំទី៧ | ៤០០ ០០០ | ៧ថ្ងៃ | |

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | គ.៣- | **ការចុះបញ្ជីគំនូសបង្ហាញនៃសៀគ្វីបង្រួម** | | | |
| ៥៥ | ១- | ការស្នើសុំចុះបញ្ជីគំនូសបង្ហាញនៃសៀគ្វីបង្រួម | ២០០ ០០០ | ១០ថ្ងៃ | |
| ៥៦ | ២- | ការផ្ដល់វិញ្ញាបនបត្រការចុះបញ្ជីគំនូសបង្ហាញនៃសៀគ្វីបង្រួម | ៦០០ ០០០ | ១០ថ្ងៃ | ១០ឆ្នាំ |
| ៥៧ | ៣- | ការបញ្ជាក់លើវិញ្ញាបនបត្រ លើការផ្លាស់ប្ដូរម្ចាស់កម្មសិទ្ធិ | ២០០ ០០០ | ១០ថ្ងៃ | |
| ៥៨ | ៤- | ការបញ្ជាក់លើឯកសារថតចម្លង | ៣០ ០០០ | ៧ថ្ងៃ | |
| ៥៩ | ៥- | ការស្ដារឡើងវិញនូវសុពលភាពការពារគំនូសបង្ហាញនៃសៀគ្វីបង្រួម | ១០០ ០០០ | ១០ថ្ងៃ | |
| | គ.៤- | **ការចុះបញ្ជីគំនូរឧស្សាហកម្ម** | | | |
| ៦០ | ១- | ការស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម | ៨០ ០០០ | ១០ថ្ងៃ | |
| ៦១ | ២- | ការផ្ដល់វិញ្ញាបនបត្រចុះបញ្ជីគំនូរឧស្សាហកម្ម រយៈពេល៥ឆ្នាំ ដំបូង | ២០០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| ៦២ | ៣- | ការចុះបញ្ជីសាឡើងវិញ រយៈពេល៥ឆ្នាំ លើកទី១ (ចាប់ពី ឆ្នាំទី៦ ដល់ ឆ្នាំទី១០) | ២០០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| ៦៣ | ៤- | ការចុះបញ្ជីសាឡើងវិញ រយៈពេល៥ឆ្នាំ លើកទី២ (ចាប់ពី ឆ្នាំទី១០ ដល់ឆ្នាំទី១៥) | ២០០ ០០០ | ១០ថ្ងៃ | ៥ឆ្នាំ |
| ៦៤ | ៧- | ការផ្ដល់វិញ្ញាបនបត្រទុតិយតាចុះបញ្ជីគំនូរឧស្សាហកម្ម | ១០០ ០០០ | ១០ថ្ងៃ | ដូចវិញ្ញាបនបត្រចាស់ |
| ៦៥ | ៥- | ការបញ្ជាក់លើឯកសារថតចម្លង | ៣០ ០០០ | ៧ថ្ងៃ | |
| ៦៦ | ៦- | ការបញ្ជាក់លើការកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណ ឬប្ដូរម្ចាស់កម្មសិទ្ធិ | ២០០ ០០០ | ១០ថ្ងៃ | |
| ៦៧ | ៨- | ការសុំកែប្រែឈ្មោះ អាសយដ្ឋាន និងការផ្លាស់ប្ដូរផ្សេងៗ របស់ភ្នាក់ងារតំណាង ឬអ្នកដាក់ពាក្យសុំ | ៤០ ០០០ | ១០ថ្ងៃ | |
| ៦៨ | ៩- | ការស្ដារឡើងវិញនូវសុពលភាពការពារគំនូរឧស្សាហកម្ម | ១០០ ០០០ | ១០ថ្ងៃ | |
| | គ.៥- | **ការបោះពុម្ពផ្សាយ និងដោះស្រាយវិវាទកម្មសិទ្ធិឧស្សាហកម្ម** | | | |
| ៦៩ | ១- | ការបោះពុម្ពផ្សាយលើការផ្ដល់ប្រកាសនីយបត្រតក្កកម្ម | ១២០ ០០០ | ៣០ថ្ងៃ | |
| ៧០ | ២- | ការបោះពុម្ពផ្សាយលើសំណុំលិខិតប្រកាសនីយបត្រតក្កកម្ម (១៨ខែ) | ១២០ ០០០ | ៣០ថ្ងៃ | |
| ៧១ | ៣- | ការបោះពុម្ពផ្សាយលើការផ្ដល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | ១២០ ០០០ | ៣០ថ្ងៃ | |
| ៧២ | ៤- | ការបោះពុម្ពផ្សាយលើសំណុំលិខិតវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (១៨ខែ) | ១២០ ០០០ | ៣០ថ្ងៃ | |
| ៧៣ | ៥- | ការបោះពុម្ពផ្សាយលើការផ្ដល់វិញ្ញាបនបត្រគំនូសបង្ហាញសៀគ្វីបង្រួម | ១២០ ០០០ | ៣០ថ្ងៃ | |
| ៧៤ | ៦- | ការបោះពុម្ពផ្សាយលើការចុះបញ្ជីគំនូរឧស្សាហម្ម ឬសាឡើងវិញ | ១២០ ០០០ | ៣០ថ្ងៃ | |
| ៧៥ | ៧- | ការបោះពុម្ពផ្សាយវិញ្ញាបនបត្រការពារពូជថ្មីនៃដំណាំ | ១២០ ០០០ | ៣០ថ្ងៃ | |
| ៧៦ | ៨- | ការប្ដឹងលើការរំលោភបំពាន និងដោះស្រាយវិវាទកម្មសិទ្ធិឧស្សាហកម្ម | ២០០ ០០០ | ៣០ថ្ងៃ | |
| | គ.៦- | **កម្រៃសេវាពាក់ព័ន្ធនឹងសំណុំឯកសារអន្តរជាតិ**(តាមប្រព័ន្ធអន្តរជាតិ) | | | |
| ៧៧ | ១- | កម្រៃសេវាបញ្ជូនឯកសារទៅអង្គការកម្មសិទ្ធិបញ្ញាពិភពលោក WIPO ឬអាជ្ញាធរស្រាវជ្រាវអន្តរជាតិ (ISA) (ក្នុងមួយឯកសារ) | ៤២០ ០០០ | ១០ថ្ងៃ | |
| ៧៨ | ២- | កម្រៃសេវានៃការទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មពីសហភាពអឺរ៉ុប នៅកម្ពុជា (១៣៥ អឺរ៉ូ) (ក្នុងមួយឯកសារ) | ៥៤០ ០០០ | ១០ថ្ងៃ | |
| ៧៩ | ៣- | ការចុះបញ្ជីគំនូរឧស្សាហកម្មថ្មីរយៈពេល ៥ឆ្នាំ ដំបូង -កម្រៃសេវាមូលដ្ឋានសម្រាប់គំនូរឧស្សាហកម្មថ្មីមួយដំបូង (៦០ CHF) (ក្នុងមួយឯកសារ) | ២៤០ ០០០ | ១០ថ្ងៃ | |
| ៨០ | ៤- | ការចុះបញ្ជីគំនូរឧស្សាហកម្មថ្មីរយៈពេល ៥ឆ្នាំ ដំបូង -កម្រៃសេវាបន្ថែមលើ គំនូរឧស្សាហកម្ម ចាប់ពី ២ ដល់ ១០០គំនូរ (២០ CHF) (ក្នុងមួយឯកសារ) | ៨០ ០០០ | ១០ថ្ងៃ | |
| ៨១ | ៥- | ការចុះបញ្ជីគំនូរឧស្សាហកម្មសាឡើងវិញ រយៈពេល ៥ឆ្នាំ លើកទី១ (ចាប់ពីឆ្នាំទី៦ ដល់ឆ្នាំទី១០) -កម្រៃសេវាមូលដ្ឋានក្នុងការចុះបញ្ជីសាឡើងវិញ សម្រាប់ពាក្យសុំមួយ (២១ CHF) (ក្នុងមួយឯកសារ) | ៨៤ ០០០ | ១០ថ្ងៃ | |

## បញ្ជីផាកពិន័យ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| លេខរៀងបទល្មើស | | ប្រភេទបទល្មើស | កម្រិតទឹកប្រាក់ដែលត្រូវពិន័យ (រៀល) |
|---|---|---|---|
| | **ក.** | **បទល្មើសទូទៅ** | |
| ១ | ១- | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ (ហួសរយៈពេល ៦ខែ) ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម និងប្រកាសនីយបត្រតក្កកម្ម (គិតក្នុង១ថ្ងៃ) | ៥០០ |
| ២ | ២- | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ (ហួសរយៈពេល ៦ខែ) ដើម្បីរក្សាសុពលភាពសំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ (គិតក្នុង១ថ្ងៃ) | ៥០០ |
| ៣ | ៣- | ការពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃសេវាប្រចាំឆ្នាំ (ហួសរយៈពេល ៦ខែ)ដើម្បីរក្សាសុពលភាពការពារពូជថ្មីនៃដំណាំ (គិតក្នុង១ថ្ងៃ) | ៥០០ |
| ៤ | ៤- | ពិន័យលើការយឺតយ៉ាវចំពោះការបង់កម្រៃនៃការចុះបញ្ជីគំនូរឧស្សាហកម្មសាឡើងវិញ ហួសរយៈពេល ៦ខែ (គិតក្នុង១ថ្ងៃ) | ៥០០ |
| | **ខ.** | **បទល្មើសដែលចែងក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម** | |
| | ១- | ក្នុងករណីបង្កើតសិប្បកម្ម ដែលតម្រូវឱ្យស្នើចុះបញ្ជី ដោយពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមូលដ្ឋាន និងពុំបានធ្វើការចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត ដែលខ្លួនបានបោះទីតាំងក្នុងរយៈពេល ០៧ថ្ងៃ ក្រោយថ្ងៃដំណើរការ (មាត្រា៤៣) | |
| ៥ | - | ផាកពិន័យលើកទី១ | ៥០០ ០០០ |
| ៦ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ១ ៥០០ ០០០ |
| ៧ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ២ ៥០០ ០០០ |
| | ២- | ក្នុងករណីបង្កើតប្រភេទសិប្បកម្ម ដែលចែងដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយគ្មានការអនុញ្ញាត (មាត្រា៤៣) | |
| ៨ | - | ផាកពិន័យលើកទី១ | ១ ០០០ ០០០ |
| ៩ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៣ ០០០ ០០០ |
| ១០ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ៥ ០០០ ០០០ |
| | ៣- | ក្នុងករណីពង្រីក ឬបង្កើតសាខា ឬផ្លាស់ប្តូរទីតាំងរោងចក្រពុំមានលិខិតអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (មាត្រា៤៤) | |
| ១១ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១២ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ១៣ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |
| | ៤- | ក្នុងករណីប្តូរម្ចាស់រោងចក្រ ម្ចាស់រោងចក្រថ្មីពុំបានធ្វើការសុំទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេល ១០ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសិទ្ធជាម្ចាស់រោងចក្រថ្មី (មាត្រា៤៤) | |
| ១៤ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១៥ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ១៦ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |
| | ៥- | ក្នុងករណីម្ចាស់រោងចក្រទទួលមរណភាព ឬអសមត្ថភាពតាមផ្លូវច្បាប់ អ្នកទទួលសិទ្ធិគ្រប់គ្រងបន្ត ពុំបានធ្វើពាក្យសុំទទួលស្គាល់ជាម្ចាស់រោងចក្រពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេល ៤៥ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលម្ចាស់រោងចក្រដើមទទួលមរណភាព ឬបាត់បង់សមត្ថភាពតាមផ្លូវច្បាប់ (មាត្រា៤៤) | |
| ១៧ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ១៨ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ១៩ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |
| | ៦- | ក្នុងករណីម្ចាស់រោងចក្រ ពុំបានជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងរយៈពេលមួយខែ មុនថ្ងៃរោងចក្របញ្ឈប់ដំណើរការជាស្ថាពរ (មាត្រា៤៤) | |
| ២០ | - | ផាកពិន័យលើកទី១ | ២ ០០០ ០០០ |
| ២១ | - | ផាកពិន័យលើកទី២ (ករណីមិនគោរពតាមការជូនដំណឹងលើកទី១) | ៦ ០០០ ០០០ |
| ២២ | - | ផាកពិន័យលើកចុងក្រោយ (ករណីមិនគោរពតាមការជូនដំណឹងលើកទី២) | ១០ ០០០ ០០០ |

ឧបសម្ព័ន្ធ១នៃប្រកាសអន្តរក្រសួងលេខ...៥៤.០៣៦ សហវ.ប្រក.អឧទ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## កម្រងសេវាសាធារណៈ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| លេខរៀងសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | **I. អគ្គនាយកដ្ឋានឧស្សាហកម្ម** | | | | |
| | **ក. នាយកដ្ឋានកិច្ចការឧស្សាហកម្ម** | | | | |
| ១ | ១- | ប្រកាសបង្កើតរោងចក្រ ឬសាខារោងចក្រ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ២ ០០០ ០០០ | ៧ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | ២- | ការផ្តល់វិញ្ញាបនបត្រថ្មី និងបន្ត (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ៨០០ ០០០ | ៧ថ្ងៃ | ៣ឆ្នាំ |
| ៣ | ៣- | លិខិតបញ្ជាក់លើ ការពង្រីកផលិតកម្ម ឬការប្តូរទីតាំងរោងចក្រ ឬការប្តូរម្ចាស់ភាគហ៊ុន ឬការប្តូរឈ្មោះរោងចក្រ ឬការបន្ថែមមុខផលិតផលថ្មី | ១ ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ៤ | ៤- | ចុះបញ្ជីរោងចក្រ (ដើមទុនលើសពី ១ ០០០ ០០០ដុល្លារអាមេរិក) | ១ ០០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ៥ | ៥- | លិខិតបញ្ជាក់ទុតិយតា | ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ៦ | ៦- | លិខិតបញ្ជាក់ផ្សេងទៀតចាំបាច់មានដូចជា ការទិញរោងចក្រ ភាពជាម្ចាស់គម្រោង ការបញ្ជាក់ទិនិញប្រភពដើម និងបរិមាណប្រើប្រាស់ និងការបញ្ជាក់ធាតុចូលផលិតកម្ម | ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| | **ខ. នាយកដ្ឋានបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម** | | | | |
| | ១- | លិខិតបញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មលើឡចំហាយ ម៉ាស៊ីនភ្លើង គ្រឿងចក្រ និងខ្សែសង្វាក់ផលិតកម្ម | | | |
| ៧ | - | រោងចក្រ | ១ ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៨ | - | សហគ្រាសធុនតូចនិងមធ្យម | ៤០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ៩ | - | សិប្បកម្ម | ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| ១០ | ២- | លិខិតបញ្ជាក់លើបរិមាណប្រើប្រាស់វត្ថុធាតុដើម ឧបករណ៍បរិក្ខារ និងមុខសញ្ញាប្រើប្រាស់-រោងចក្រ | ១ ៥០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ១១ | ៣- | លិខិតបញ្ជាក់លើបរិមាណប្រើប្រាស់វត្ថុធាតុដើម ឧបករណ៍បរិក្ខារ និងមុខសញ្ញាប្រើប្រាស់-សហគ្រាសធុនតូចនិងមធ្យម | ៤០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ១២ | ៤- | លិខិតបញ្ជាក់លើបរិមាណប្រើប្រាស់វត្ថុធាតុដើម ឧបករណ៍បរិក្ខារ និងមុខសញ្ញាប្រើប្រាស់-សិប្បកម្ម | ២០០ ០០០ | ៧ថ្ងៃ | តាមការស្នើសុំ |
| ១៣ | ៥- | លិខិតបញ្ជាក់លើការរៀបចំប្រព័ន្ធប្រព្រឹត្តកម្ម ការទុកដាក់សំណល់រាវ សំណល់រឹង ឧស្ម័ន និងប្រព័ន្ធលំហូរខ្យល់ ដែលខុសពីលក្ខណៈបច្ចេកទេស ដែលកំណត់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១ ២០០ ០០០ | ៧ថ្ងៃ | ១ឆ្នាំ |
| | **គ. នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម** | | | | |
| | **គ.១- ការផ្តល់ប្រកាសនីយបត្រតក្កកម្ម** | | | | |
| ១៤ | ១- | ការស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម-សេចក្តីអះអាង ១០ដំបូង | ៣២០ ០០០ | ១០ថ្ងៃ | |
| ១៥ | ២- | ការស្នើសុំផ្តល់ប្រកាសនីយបត្រតក្កកម្ម-សេចក្តីអះអាងលើសពី ១០ដំបូង | ២០ ០០០ | ១០ថ្ងៃ | |
| ១៦ | ៣- | ការផ្តល់ប្រកាសនីយបត្រតក្កកម្ម | ៦០០ ០០០ | ១០ថ្ងៃ | ២០ឆ្នាំ |
| ១៧ | ៤- | ការផ្តល់វិញ្ញាបនបត្រទុតិយតាប្រកាសនីយបត្រតក្កកម្ម និងម៉ូដែលមានអត្ថប្រយោជន៍ | ១០០ ០០០ | ១០ថ្ងៃ | ដូចវិញ្ញាបនបត្រចាស់ |
| ១៨ | ៥- | ការផ្តល់អាជ្ញាបណ្ណបញ្ញា | ១ ៥០០ ០០០ | ១០ថ្ងៃ | ២ឆ្នាំ |
| ១៩ | ៦- | ការបញ្ជាក់លើការកត់ត្រាកិច្ចសន្យាអាជ្ញាបណ្ណ ឬប្តូរម្ចាស់កម្មសិទ្ធិ | ២៨០ ០០០ | ១០ថ្ងៃ | |
| ២០ | ៧- | ការបញ្ជាក់លើឯកសារប្រកាសសិទ្ធិអាទិភាព | ៣០០ ០០០ | ១០ថ្ងៃ | |
| ២១ | ៨- | ការសុំកែប្រែឈ្មោះ អាសយដ្ឋាន និងការផ្លាស់ប្តូរផ្សេងៗ របស់ភ្នាក់ងារតំណាង ឬអ្នកដាក់ពាក្យសុំ | ៤០ ០០០ | ១០ថ្ងៃ | |
| ២២ | ៩- | ការស្តារឡើងវិញនូវសុពលភាពការពារប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | ១០០ ០០០ | ១០ថ្ងៃ | |